ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៣៩៨ សហវ.ឯលស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

**កម្មវត្ថុ**: ករណីសំណើសុំការអនុញ្ញាតសម្រេចជ្រើសរើសនិងប្រគល់កិច្ចសន្យា ស្តីពីការងាររៀបចំមន្ទីរពិសោធន៍ផលិតថ្នាំ, រៀបចំមជ្ឈមណ្ឌលប្រឡងកុំព្យូទ័រ និងរៀបចំមជ្ឈមណ្ឌលមន្ទីរពិសោធន៍បង្ហាញគ្រាប់ នៅអគារ ADB និងអគារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (អគារទី២) ។

**យោង** :
- លិខិតលេខ១៦១៥ ស.វ.ស ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- លិខិតលេខ៦៥៩ សនថហ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងសុខាភិបាល
- កំណត់ហេតុបើកឯកសារដេញថ្លៃចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- លិខិតលេខ១៤៩ អល/ ស.វ.ស ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមសាកលវិទ្យាធិការមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្នុងការប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន គីម ហួយ អ៊ាង អ៊ីមផត អិចផត អេន ខនស្ត្រាក់សិន ដើម្បីរៀបចំមន្ទីរពិសោធន៍ផលិតថ្នាំ, រៀបចំមជ្ឈមណ្ឌលប្រឡងកុំព្យូទ័រ និងរៀបចំមជ្ឈមណ្ឌលមន្ទីរពិសោធន៍បង្ហាញគ្រាប់ នៅអគារ ADB និងអគារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (អគារទី២) ក្នុងតម្លៃសរុបចំនួន ១ ៤៤៩ ១៦០ ៩០០ រៀល (មួយប៊ីលាន បួនរយសែសិបប្រាំបួនលាន មួយរយហុកសិបពាន់ប្រាំបួនរយរៀលគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមសាកលវិទ្យាធិការមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមសាកលវិទ្យាធិការទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហ៊ីង សុវណ្ណ

**ចម្លងជូន**:
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមហ៊ុន គីមហួយ អ៊ាង អ៊ីមផត អិចផត អេន ខនស្ត្រាក់សិន
- ឯកសារ-កាលប្បវត្តិ